# ខ្មែរគ្រប់រូប

# ត្រៀមឃចាំ!



AFP File Photo

*រថក្រោះរបស់កងទាហានស្មោះនឹងនាយករដ្ឋមន្ត្រីទី២ ហ៊ុន សែន ក្នុងព្រឹត្តិការណ៍បង្ហូរឈាមកណ្តាលក្រុងភ្នំពេញ នាថ្ងៃ៥-៦ កក្កដា ១៩៩៧ ។*

## ការធ្វើសម្ភាសន៍របស់កាសែតភ្នំពេញប៉ុស្តិ៍

### លោក Jason Barber អ្នកកាសែតPhnom Penh Post ធ្វើសម្ភាសន៍ជាមួយឧត្តមសេនីយ ញឹក ប៊ុន ឆាយ នៅភូមិអូរស្មាច់នៅថ្ងៃទី៨ ខែសីហា



"លោក ញឹក ប៊ុន ឆាយ ដែលមានរូបរាងស្គមជាងមុន បាន ប្រកាសបន្តការតស៊ូ" ។

*ប្រែសម្រួលក្រៅផ្លូវការដោយ ហ្វូរ៉ុប*

សួរថាតើការរត់ចេញពីភ្នំពេញជាដំណើរដែលមានគ្រោះថ្នាក់បំផុតក្នុងជីវិតទាហានរបស់លោក លោក ញឹក ប៊ុន ឆាយ ផ្អែកទៅនឹងកៅអីរបស់គាត់ ញញឹមយ៉ាងមាំទៅអ្នកកាសែតហើយនិយាយថា "បាទមែន" ។ ក្រោយរយៈពេល ១៧ថ្ងៃដែលលោកបានរត់គេចគ្មានដំណឹងសូន្យ លោក ញឹក ប៊ុន ឆាយ បានបង្ហាញខ្លួននៅតាមព្រំប្រទល់ខ្មែរ-ថៃ អស់កម្លាំង ស្គមជាងមុន ហើយមានជម្ងឺគ្រុនចាញ់ ។ លោកនាយទាហានហ៊ិនស៊ុនប៉ិចនិយាយប្រាប់លោក Jason Barber នៅតាមព្រំប្រទល់ភូមិអូរស្មាច់នៅថ្ងៃទី៨ ខែសីហា ។

**ប៊ុនឆាយ:** ខ្ញុំចេញពីភ្នំពេញនៅថ្ងៃទី៦ ហើយមកដល់កន្លែងនេះនៅថ្ងៃទី២៣ ខែកក្កដា ។ ការធ្វើដំណើររបស់ខ្ញុំមានការលំបាកយ៉ាងខ្លាំង ពួកគេ (CPP) ប្រើទាហានយ៉ាងច្រើនចំនួនប្រហែល៣ទៅ៤ពាន់នាក់ដើម្បីតាមចាប់ខ្ញុំ ។ ពេលដែលខ្ញុំចាកចេញពីភ្នំពេញ យើងមានទាហាន៤០០នាក់មកតាមខ្ញុំ ។ ដោយសារការរត់លួនមានគ្នាច្រើន មានការពិបាកក្នុងការលាក់ខ្លួន យើងក៏បំបែកគ្នា ។ យើងចែកគ្នាជាកងតូចៗ ។ ទាហានខ្លះបានលាក់អាវុធហើយប្តូរឯកសណ្ឋានជាជនសាមញ្ញ ។ មានទាហាន៧០នាក់រត់មកជាមួយកងរបស់ខ្ញុំ ។ ទាហានហ៊ុនសែន បានវាយប្រហារមកលើយើង៤ឬ៥ដង ។ គេចាប់ឬក៏សម្លាប់ទាហានជាច្រើនដែលមកជាមួយខ្ញុំ ។ ពេលដែលយើងមកដល់អូរស្មាច់នេះ សល់តែ៣នាក់គត់ ។ ពីរនាក់គឺជាអង្គរក្សរបស់ខ្ញុំ ហើយម្នាក់ទៀតគឺខ្ញុំ ។ ខ្ញុំសូមបញ្ចេញឈ្មោះអ្នកខ្លះដែលត្រូវបក្សពួកហ៊ុនសែនចាប់សម្លាប់ លោក ក្រូច យឿម, លី សៀងហុង, ម៉ែន ប៊ុនថន, ចៅ សម្បត្តិ និងលោកឧត្តមសេនីយ ថ្លាង សុវណ្ណរិទ្ធ ពីខេត្តបាត់ដំបង ។ អ្នកទាំងអស់នោះបានត្រូវគេសម្លាប់ ។ របៀបដែលគេសម្លាប់អ្នកទាំងនោះ គឺសាហាវព្រៃផ្សៃជាទីបំផុត ។ ពួកយើងបានប្រាប់ខ្ញុំថា ឧត្តមសេនីយ៍ ចៅ សម្បត្តិ ត្រូវគេធ្វើទារុណកម្មដោយទាញក្រចកហើយប្រើដង្កាប់ទាញអណ្តាតចេញហើយកាត់អណ្តាតចោល ។ អ្នកទាំងអស់ទៀតត្រូវគេចាប់ចងហើយបាញ់ចោល ។ ខ្ញុំបានធ្វើដំណើរ (១៥ថ្ងៃ) ពីភ្នំពេញទៅដល់ពោធិសត្វថ្ងៃទី២១ ខែកក្កដា ។ ពីពោធិសត្វមកកន្លែងនេះ ខ្ញុំជិះម៉ូតូ ។ ចំណាយពេលអស់ពីរថ្ងៃ ។ មានទាហានហ៊ុនសែនខ្លះដែលនៅស្រឡាញ់ហើយជឿខ្ញុំ បានជួយខ្ញុំ។

**BARBER:** តើគេជួយលោកយ៉ាងម៉េច ?

**ប៊ុនឆាយ:** គេឲ្យខ្ញុំជិះម៉ូតូ ។ អញ្ចឹងហើយទើបបានខ្ញុំមកដល់កន្លែងនេះ ។

**BARBER**: មានពាក្យចចាមអារ៉ាមជាច្រើនដែលគេនិយាយអំពីលោក, ក្នុងចំណោមអ្នកទាំងនោះ មានទាហានខ្លះដែលរត់ជាមួយលោកហើយត្រូវគេចាប់បាន ។ រឿងដែលគេនិយាយថា លោកត្រូវគេបាញ់ចំខ្នង ស្រាប់តែដួលហើយក្រោករត់ទៅទៀត ?

*តទៅទំព័រទី ១០ (ញ)*

*...តមកពីទំព័រទី ៤ (ញ)* សម្ភាសន៍ ញឹក ប៊ុន ឆាយ

<u>ម៊ុនឆាយ:</u> ទេ! ទេ! បាញ់នោះ បាញ់ជិតខ្ញុំមែន ប៉ុន្តែគេមិនមែនបាញ់ខ្ញុំទេ។ គេ បាញ់៥ឬ១០ម៉ែត្រពីខ្ញុំ ។

**<u>BARBER:</u>** រឿងមួយទៀតគេនិយាយថាលោកបានដោះអាវក្រោះការពារគ្រាប់ (Bullet-Proof Jacket) ដូរយកអាវធម្មតាដែលមានមន្តអាគម ?

<u>ម៊ុនឆាយ:</u> បាទ! ត្រូវហើយ (សើច) ។ នៅពេលមួយដែលយើងកំពុងតែរត់ ខ្ញុំនិងកូនទាហានខ្ញុំម្នាក់ពួននៅនឹងគុម្ពឈើប្រហែលជាពីរម៉ែត្រក្រឡា(បួនជ្រុង)។ ពួកទាហានហ៊ុន-សែនដើរផុតពីយើងប្រហែលជាបីទៅប្រាំម៉ែត្រពីយើង ។ តែគេរកយើងមិនឃើញ ។ ពីមុនមកពួកខ្ញុំមិនដែលជឿលើមន្តអាគមនេះទេ ប៉ុន្តែឥឡូវខ្ញុំជឿថាមានវត្ថុសក្តិសិទ្ធិជួយថែរក្សាខ្ញុំ ។

**<u>BARBER:</u>** តើពេលនោះជាពេលដែលពិបាក គ្រោះថ្នាក់បំផុតក្នុងឆាកជីវិតទាហានរបស់លោក ?

<u>ម៊ុនឆាយ:</u> បាទ...ពិបាក ។ ខ្ញុំអត់មានស្អីចូលពោះមួយអាទិត្យ ។ ខ្ញុំអត់មានរបួស...ប៉ុន្តែខ្លួនប្រាណហេវហត់អស់កម្លាំងខ្លាំង (សើច) ។ ខ្ញុំមានជម្ងឺគ្រុនចាញ់ នៅពេលដែលខ្ញុំធ្វើដំណើរ ប៉ុន្តែខ្ញុំសំណាងណាស់ដែលជម្ងឺនោះវាមិនខ្លាំង ។ ពេលដែលខ្ញុំមកដល់កន្លែងនេះ ខ្ញុំដេកពីរថ្ងៃ ។

**<u>BARBER:</u>** តើលោកដឹងទេថាទម្ងន់លោកចុះប៉ុន្តែគីឡូ ?

<u>ម៊ុនឆាយ:</u> ១៥គីឡូ។ ពីមុនខ្ញុំមានទម្ងន់៨០គីឡូ តែឥឡូវនៅសល់តែ៦៥ទេ ។

**<u>BARBER:</u>** ពេលដែលលោកកំពុងតែរត់ តើលោកមានខ្វាយខ្វល់គិតពីរឿងអ្វីៗទាំងអស់នេះទេ ? តើអ្វីទៅដែលធ្វើឲ្យលោកមានចិត្តបន្តទៅមុខ ?

<u>ម៊ុនឆាយ:</u> ស្អីដែលធ្វើឲ្យខ្ញុំមានចិត្តបន្តការតស៊ូគឺប្រជាជនជាច្រើនជាពិសេសសមាជិកខាងបក្សប្រឆាំងដូចជា គណបក្សរជបខ(BLDP), គណបក្សហ៊្វុនស៊ិនប៉ិច(FUNCINPEC), គណបក្សជាតិខ្មែរ(KNP) បានត្រូវគេគំរាមសម្លាប់ ហើយធ្វើបាបដោយលោកហ៊ុន-សែន ។ ដូច្នេះហើយខ្ញុំប្តេជ្ញាចិត្តថាខ្ញុំត្រូវតែរស់ដើម្បីរត់ទៅអូរស្មាច់ការពារប្រជាជនដែលត្រូវការលទ្ធិប្រជាធិបតេយ្យនិងសេរីភាព។ ខ្ញុំសូមប្រកាសដោយច្បាស់លាស់ថា ខ្ញុំប្រយុទ្ធដើម្បីសិទ្ធិសេរីភាព, ដើម្បីលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជា ។ ល្បែងដែលហ៊ុន-សែនលេងគឺជាល្បិចដូចជាល្បែងឆ្អិនឆ្អៅកគេ ដែលបន្លំគេថាខ្លួនមានលទ្ធិប្រជាធិបតេយ្យ ។ ប៉ុន្តែគ្មានលទ្ធិប្រជាធិបតេយ្យអ្វីទាំងអស់ ។ ប្រជាជនត្រូវគេធ្វើបាបហើយគំរាមកំហែង។ ប្រជាជនទាំងនេះយើងត្រូវការពារ។ ខ្ញុំជឿក្នុងចិត្តថា អំពើល្អនឹងឈ្នះអំពើអាក្រក់ ហើយខ្ញុំជឿជាក់ថាការប្រយុទ្ធរបស់យើងដើម្បីស្វែងរកលទ្ធិប្រជាធិបតេយ្យនិងសេរីភាពនឹងបានឈ្នះថ្ងៃណាមិនខាន ហើយយើងនឹងមានលទ្ធិប្រជាធិបតេយ្យពិតៗនិងសន្តិភាពសម្រាប់ខ្មែរទាំងអស់ ។

ហើយខ្ញុំចង់ជំរាបលោកថាតើហេតុអ្វីហ៊ុន-សែនប្រើកម្លាំងទាហានកំចាត់ពួកហ៊្វុនស៊ិនប៉ិចចេញពីភ្នំពេញ ។ ចំណុចសំខាន់ទីមួយគឺហ៊ុន-សែនចោទពួកយើងក្នុងការចរចារជាមួយពួកខ្មែរក្រហមនៅអន្លង់វែង ។ យើងចរចារដើម្បីសន្តិភាព ដើម្បីទាក់ទាញពួកគេឲ្យចូលរួមក្នុងរាជរដ្ឋាភិបាលដូចជានៅកន្លែងផ្សេងៗដែលហ៊ុន-សែនបានធ្វើមកហើយនៅភ្នំម៉ាឡៃ និងបរប៉ៃលិន។ ការសំខាន់មួយទៀតគឺយើងចង់យកប៉ុល-ពតប្រគល់ទៅឲ្យតុលាការអន្តរជាតិ។ យើងមិនចង់យកប៉ុលពតទៅឲ្យតុលាការនៅភ្នំពេញទេ។ តុលាការនៅភ្នំពេញគ្មានភាពឯករាជ្យហើយគ្មានយុត្តិធម៌។ ហើយហ៊ុន-សែនគាត់ខ្លាច មិនចង់យកប៉ុល-ពតទៅឲ្យតុលាការអន្តរជាតិ។ ប៉ុល-ពតបានប្រកាសយ៉ាងច្បាស់លាស់ថាគាត់នឹងទទួលខុសត្រូវលើអ្វីៗដែលបានកើតឡើងនៅជំនាន់ប៉ុល-ពត។ អាជ្ញាធរដែលសម្លាប់ខ្មែរនៅពេលនោះគឺជាពួកខ្មែរក្រហមដែលរួមសម្ព័ន្ធជាមួយវៀតណាម។ ហ៊ុន-សែនជាខ្មែរក្រហមម្នាក់ដែលរួមសម្ព័ន្ធជាមួយវៀតណាម គាត់មានចំណែកក្នុងការទទួលខុសត្រូវលើប្រជាជនខ្មែរដែលត្រូវគេសម្លាប់ក្នុងឆ្នាំ១៩៧៥។ ហ៊ុន-សែនខ្លាចណាស់ថាបើប៉ុល-ពតត្រូវបានគេបញ្ជូនទៅវិនិច្ឆ័យទោស គេនឹងហៅឈ្មោះគាត់(ហ៊ុន-សែន) ហើយបង្ហាញថាគាត់បានចូលរួមក្នុងការកាប់សម្លាប់ប្រជារាស្ត្រខ្មែរដែរ។ ខ្មែរក្រហមនៅអន្លង់វែងបានប្រែប្រួលតាំងពីប៉ុល-ពតត្រូវគេចាប់ខ្លួន គេបានផ្លាស់ប្តូរប្រព័ន្ធនយោបាយ គេចង់ចូលរួមជាមួយនឹងរាជរដ្ឋាភិបាល។ ក្នុងពេលឥឡូវនេះគេចង់រៀបចំសារជាថ្មី ហើយប្តូរឯកសណ្ឋាន គឺឯកសណ្ឋានចាស់ទៅឯកសណ្ឋានថ្មី។ ឥឡូវយើងនៅតែបន្តសាកល្បងបញ្ជូនប៉ុល-ពតទៅឲ្យតុលាការអន្តរជាតិវិនិច្ឆ័យទោស ។

ហេតុទីពីរ ដែលហ៊ុន-សែនវាយកំទេចហ៊្វុនស៊ិនប៉ិច គឺជារឿងរត់ពន្ធគ្រឿងញៀន។ យើងបានរកឃើញសំណុំរឿងដែលយើងបញ្ជូនទៅឲ្យទូតបរទេសបានបង្ហាញថាអ្នកដែលទាក់ទងរត់គ្រឿងញៀនគឺអស់លោកធំៗ ដូចជាថេង-ប៊ុនម៉ា និង ម៉ុង-រិទ្ធី។ ហេតុនេះហើយបានជានៅពេលដែលគេចាប់រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ហូ-សុខ ហ៊ុន-សែន បានបញ្ជាឲ្យហុក-ឡង់ឌី ទៅសម្លាប់ហូ-សុខ ភ្លាម ពីព្រោះ ហូ-សុខ មានសំណុំរឿងជាច្រើនអំពីគ្រឿងញៀន។ លុយដែលបានមកពីគ្រឿងញៀន ហ៊ុន-សែន យកទៅសង់សាលារៀន ទៅចរចារជាមួយពួកខ្មែរក្រហម ទៅឲ្យអ្នករាជការខ្លះៗ ។ លុយខ្លះទៀតគាត់ឲ្យទៅអ្នករាជការថៃ ឲ្យជួយគាំទ្រគាត់ដើម្បីកៀបសង្កត់មកលើយើង។ មន្ត្រីផ្លូវការរបស់ហ៊្វុនស៊ិនប៉ិចខ្លះទៀតដែលបានភៀសខ្លួនដល់ប្រទេសថៃត្រូវរាជការថៃគំរាមកំហែងបញ្ជូនត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញហើយត្រូវហ៊ុនសែនសម្លាប់ចោលអស់។

**<u>BARBER:</u>** តើលោកអាចឲ្យឈ្មោះអ្នកដែលត្រូវគេសម្លាប់មកខ្ញុំបានទេ ?

<u>ម៊ុនឆាយ:</u> មានច្រើន ប៉ុន្តែខ្ញុំមិនចាំឈ្មោះអ្នកទាំងនោះទេ។ ហេតុទីបី គឺជារឿងបោកគ្រាប់បែកនៅថ្ងៃទី៣០ ខែមិនា នៅទីក្រុងភ្នំពេញ។ ក្រោយការស៊ើបអង្កេតភ្នាក់ងារ FBI បានរកឃើញថាអង្គរក្សរបស់ហ៊ុន-សែនជាអ្នកសង្ស័យទីមួយ។ ហ៊ុន-សែនមានសេចក្តីបារម្ភជាខ្លាំង។

រឿងទីបួន គឺការបោះឆ្នោត។ ហ៊ុន-សែនបានដឹងមុនថាខ្លួននឹងត្រូវចាញ់ឆ្នោត។ គាត់និយាយថាគាត់ចង់ឲ្យមានការបោះឆ្នោត ប៉ុន្តែគាត់មិនដែលចង់ចាញ់ឆ្នោតទេ។ ចំណុចទាំងអស់នេះ ធ្វើឲ្យហ៊ុន-សែនប្រើកម្លាំងយោធា ។

**<u>BARBER:</u>** តើលោកមានដឹងមុនថា ហ៊ុន-សែននឹងវាយហ៊្វុនស៊ិនប៉ិចនៅភ្នំពេញទេ ?

ប៊ិនឆាយ: បាទ! ខ្ញុំដឹង។ ខ្ញុំដឹងថាពេលដែលហ៊ុន-សែនទៅហាណូយ (ស្រុកយួន) ទៅសុំរដ្ឋាភិបាលវៀតណាមឲ្យជួយផ្តល់គ្រាប់កាំភ្លើងនិងកម្លាំងទ័ព។ គាត់សុំប្រើកងទ័ពសម្ងាត់វៀតណាមដែលនៅភ្នំពេញ ធ្វើការខាងសំណង់ និងធ្វើការនៅរោងចក្រកៅស៊ូ និងខ្លះទៀតធ្វើជាអ្នកបើកម៉ូតូ។ ជនជាតិវៀតណាមទាំងនោះមានចំនួនប្រហែល៥០០០នាក់។ នៅវត្តមួយនៅតាមផ្លូវជាតិលេខ១ មានផ្នូរខ្មោចទាហានវៀតណាមជាច្រើននៅកន្លែងនោះ ប៉ុន្តែផ្នូរខ្មោចខ្លះមិនមែនកប់មនុស្សស្លាប់ទេ គឺកប់កាំភ្លើង ពួកទាហានសម្ងាត់វៀតណាមជីកយកកាំភ្លើងទាំងនោះទៅប្រើ ។

*តទៅទំព័រទី ១១ (ញ)* ញឹក ប៊ុន ឆាយ

*...តមកពីទំព័រទី ១០ (ញ)* ញ៉ឹក ប៊ុន ឆាយ

**BARBER:** លោកជឿថាកងទ័ពសម្ងាត់វៀតណាមមានចំណែកក្នុងការវាយ ...ន្ទីរតាំងក្រសាំង ?

**...ុនឆាយ:** បាទ! ជឿ ។

**BARBER:** មានគ្រាប់ផ្លោងយ៉ាងខ្លាំងនៅតាំងក្រសាំង។ នៅពេលនោះតើលោកគិតថាលោកប្រហែលជាស្លាប់នៅកន្លែងនោះ ?

**...ុនឆាយ:** បាទ! មែន ខ្ញុំព្រួយ ។ ប៉ុន្តែខ្ញុំសំរេចចិត្តវាយចេញទៅជួបប្រជាជននៅ...ុះសម្តេចនរោត្តរណឫទ្ធ ពីព្រោះគេត្រូវការជំនួយ។ ខ្ញុំមិនទាន់ទៅដល់ផង កង...ាហានទាំងនោះខ្លាច (ហើយចុះចាញ់ទៅ) ។

**BARBER:** លោកនិយាយថាលោកហ៊ុន-សែន បានទិញមេទាហានធំៗរបស់...ហ្វ៊ុនស៊ិនប៉ិច។ តើនេះជាកត្តាមួយដែលធ្វើឲ្យកងទ័ពហ្វ៊ុនស៊ិនប៉ិចចុះចាញ់យ៉ាង...ាប់រហ័សនៅភ្នំពេញ ?

**...ុនឆាយ:** ខ្ញុំមានសេចក្តីទោមនិញតែបន្តិចបន្តួចតែប៉ុណ្ណោះ ចំពោះមេទាហាន...ធំៗរបស់ហ្វ៊ុនស៊ិនប៉ិចដែលត្រូវគេទិញបាន។ មានតែមួយចំនួនតូចទេបាទ! ។

**BARBER:** នៅភ្នំពេញ ពេលដែលកំពុងវាយគ្នា តើលោកគិតថាលោកមានសមត្ថភាពការពារមិនឲ្យរបូតកន្លែងខ្លះនៅភ្នំពេញបានយូរឬទេ ?

**ម៊ុនឆាយ:** បាទ, ពេលដំបូងខ្ញុំជឿជាក់ថាខ្ញុំអាចរក្សាទប់ទល់កន្លែងខ្លះនៅភ្នំពេញ។ ប៉ុន្តែក្រោយមកខ្ញុំដឹងថា បើសិនណាជាខ្ញុំនៅតែបន្តទប់ទល់ មានមនុស្សជាច្រើនដែលត្រូវស្លាប់។ អញ្ចឹងហើយបានជាខ្ញុំសម្រេចចិត្តដកថយ។ ហើយយើងឮថាសម្តេចនរោត្តមសីហនុ និង ជា-ស៊ីម បានសូមឲ្យឈប់បាញ់គ្នា។ ពួកយើងបានបញ្ឈប់ការបាញ់គ្នា ។

**BARBER:** តើលោកមានប្រតិកម្មយ៉ាងម៉េចចំពោះការប្រហារជីវិតនៃជន...ខ្លះដូចជាលោក ហូ-សុខ ?

**ម៊ុនឆាយ:** ខ្ញុំមានការខកចិត្តនិងរកាំចិត្តយ៉ាងខ្លាំង។ ខ្ញុំមានការសោកស្តាយហើយនិងភ្ញាក់ផ្អើលដែលលោកហ៊ុន-សែនបានសម្លាប់មនុស្សជាច្រើន។ ខ្ញុំធ្លាប់គិតថាប៉ុល-ពត ជាមេឃាតករយ៉ាងអាក្រក់បានសម្លាប់មនុស្សជាច្រើន។ ប៉ុន្តែក្នុងពេលវាយគ្នានិងក្រោយមក ខ្ញុំឃើញថាលោកហ៊ុន-សែន អាក្រក់ជាងប៉ុល-ពត មួយរយដង។ គាត់មិនត្រឹមតែសម្លាប់លោក ហូ-សុខ ទេ តែជនស្លូតត្រង់ជាច្រើន។ កងទាហានរបស់លោកហ៊ុន-សែន មិនត្រឹមតែសម្លាប់មនុស្សប្រុសៗទេ គេសម្លាប់ទាំងគ្រួសាររបស់ទាហានហ្វ៊ុនស៊ិនប៉ិចទៀត។ ទាំងគ្រួសារតាំងពីស្ត្រីនិងកូនក្មេងក៏មិនទុកឲ្យរស់ដែរ។ ស្ត្រីខ្លះបានត្រូវកងទ័ពរបស់លោកហ៊ុន-សែនរំលោភនៅ សំរោង និងសៀមរាប ។

**BARBER:** ខ្ញុំសន្មត់ជាមុនថាលោកបានជួបលោក សេរី កុសល លោក ឡាយវីរៈ តាំងពីលោកមកដល់។ តើគេមានសេចក្តីភ្ញាក់ផ្អើលដែលឃើញលោកនៅរស់ ?

**ម៊ុនឆាយ:** បាទ ពួកម៉ាកចាស់ៗរបស់ខ្ញុំសឹងតែទាំងអស់មានសេចក្តីភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលឃើញខ្ញុំនៅរស់។ មិនត្រឹមតែពួកម៉ាកខ្លះដែលលោកមានប្រសាសន៍នោះទេ សូម្បីតែកូនទាហានក៏ភ្ញាក់ផ្អើលដែរ។ គេមានកម្លាំងទឹកចិត្តប្រយុទ្ធការពារលទ្ធិប្រជាធិបតេយ្យ ។

**BARBER:** តើកងទ័ពរបស់លោកហ៊ុន-សែន នៅឆ្ងាយពីកន្លែងនេះប្រហែលប៉ុន្មាន ? តើគេសាកល្បងវាយយកអូរស្មាច់ទេ ?

**ម៊ុនឆាយ:** ពីកន្លែងនេះទៅដល់កងទ័ពលោកហ៊ុន-សែន ប្រហែលជា៥០គីឡូម៉ែត្រ។ ខ្ញុំជឿជាក់ថាកងកម្លាំងរបស់លោកហ៊ុន-សែន មិនអាចចូលមកយកកន្លែងនេះទេ។ ពួកទាហានយើងមានកំហឹងហើយមានសេចក្តីឈឺចាប់យ៉ាងខ្លាំងចំពោះអ្វីៗដែលលោកហ៊ុន-សែន បានធ្វើ។ យើងមានសេចក្តីទុកចិត្តយ៉ាងមាំថាយើងអាចផ្តល់ការការពារដល់ប្រជាជននៅកន្លែងនេះ។ ប៉ុន្តែថ្ងៃមុនមានការប្រយុទ្ធតូចមួយ។ ប៉ុន្តែខ្ញុំជឿថាក្នុងប៉ុន្មានថ្ងៃទៀត លោកហ៊ុន-សែននឹងបញ្ជូនទាហានប្រហែលជា ៣០០០នាក់ មកវាយយើង ។

**BARBER:** តើលោកមានទាហានប៉ុន្មាននាក់ ?

**ម៊ុនឆាយ:** ឥឡូវនេះ នៅកន្លែងនេះ យើងមាន ២៥០០០នាក់ ។

**BARBER:** តើលោកមានគ្រាប់កាំភ្លើង និងម្ហូបអាហារប៉ុន្មាន ?

**ម៊ុនឆាយ:** គ្រប់គ្រាន់នឹងរស់បានបីខែ ។

**BARBER:** តើលោកគិតថាអាចមានដំណោះស្រាយខាងផ្លូវទូត, នយោបាយដើម្បីអនុញ្ញាតិឲ្យទ្រង់រណឫទ្ធ និងអ្នកធំៗខាងហ្វ៊ុនស៊ិនប៉ិចឯទៀតត្រឡប់ចូលភ្នំពេញវិញ ឬក៏លោកគិតថាគ្មានសង្ឃឹម លើកលែងតែប្រើកម្លាំងកងទ័ព ?

**ម៊ុនឆាយ:** ខ្ញុំចង់ដោះស្រាយបញ្ហានេះដោយផ្លូវទូត ឬដោយសន្តិវិធី។ យើងមិនចង់ប្រើកម្លាំងទ័ពទេ។ ប៉ុន្តែយើងត្រូវតែទុកកម្លាំងកងទ័ពខ្លះដើម្បីការពារ ។

*តទៅទំព័រទី ១២ (ញ)* ញ៉ឹក ប៊ុន ឆាយ

*...តមកពីទំព័រទី ៩ (ស)*

ទេសខ្មែរ។ ប្រជាជនចង់បានការផ្លាស់ប្តូរធំៗ។ ការបោះឆ្នោតចំពោះប្រជាជនខ្មែរ ជាការជ្រើសរើសបែបសង្គមដែលគេចង់រស់នៅ ។ បើគេសួរប្រជាជនថៃសំនួរដដែលនេះ ហើយដែលត្រូវចំកន្លែងផ្លាស់ប្តូរដូចខ្មែរ ខ្ញុំជឿច្បាស់ណាស់ថាគេនឹងចង់ជ្រើសរើសជីវិតរបស់គេ។ ហើយមធ្យោបាយតែមួយគឺការជ្រើសរើសតាមការបោះឆ្នោត ។

<u>សំនួរ:</u> តើលោកគិតថាលោកអាចដឹកនាំប្រទេសបានឬទេ ?

<u>លោក សម-រង្ស៊ី:</u> ចំណុចគន្លឹះដើម្បីដឹកនាំប្រទេសឲ្យបានជោគជ័យ គឺត្រូវមានការគោរពច្បាប់។ បើគ្មានច្បាប់ គ្មាននរណាធ្វើអ្វីបានទេ។ ប្រទេសនឹងបាក់បែកខ្ទេចខ្ទី។ ដូច្នេះខ្ញុំសង្ឃឹមថាសហគមន៍អន្តរជាតិនឹងមានភាពទៀតទាត់ពេលដែលគេជួយខ្មែរ។ គេត្រូវលើកដំកើងនិងការពារការគោរពច្បាប់។ បើអ្នកចង់ជួយប្រទេស សូមគិតឲ្យច្បាស់អំពីក្បួនច្បាប់មុនគេ ។

<u>លោកស្រី ជូឡុង សាម្ហួរ៉ា:</u> សំនួរមិនគ្រាន់តែចង់ដឹងថា តើគាត់អាចដឹកនាំប្រទេសបានឬអត់នោះទេ ប៉ុន្តែគាត់ជាខ្មែរតែម្នាក់គត់បំរើប្រទេសពេលនេះ ។ ខ្ញុំមិនឃើញមាននរណាម្នាក់គ្រាន់បើជាងគាត់ទេ។ ខ្ញុំបានឃើញអ្វីដែលគាត់បានធ្វើនៅក្រសួងហិរញ្ញវត្ថុ។ ក្នុងរយៈពេល២ខែប៉ុណ្ណោះ គាត់បានតំឡើងប្រាក់បង់ពន្ធគយឡើង២ដង ហើយក្នុងពេល៣ខែ បានឡើង៣ដង ។

គាត់មិនបានផ្លាស់ប្តូរមនុស្សក្នុងក្រសួងទេ។ ករិតបង់ពន្ធនិងមនុស្សនៅដដែល។ គាត់គ្រាន់តែមានប្រសាសន៍ថា "ពីពេលនេះតទៅម្នាក់ៗត្រូវតែស្អាតស្អំ" ហើយខ្លួនគាត់ក៏ស្អាតស្អំដែរ។ គ្មាននរណាមានសមត្ថភាពដូចគាត់ទេ។ គាត់មានគ្រប់មុខ៖ សេចក្តីក្លាហាន ការប្តេជ្ញាចិត្ត និងភាពស្មោះត្រង់ ។

...តមកពីទំព័រទី ១១ (ញ) ញឹក ប៊ុន ឆាយ

**BARBER:** តើលោកមានគិតចង់ប្រមូលផ្តុំកម្លាំងដើម្បីវាយឆ្មក់ទៅលើកងទ័ពរបស់លោកហ៊ុន-សែន ទេ ?

**ញ៉ុនឆាយ:** យើងមិនចង់ធ្វើសកម្មភាពទេ យើងមិនចង់ធ្វើឲ្យប្រជាជនស្លាប់ ។ យើងគ្រាន់តែចង់ការពារទឹកដីរបស់យើងតែប៉ុណ្ណោះ ហើយមើលតើយើងត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយដោយសន្តិវិធី ។

**BARBER:** តើលោកមានបានជួប ឬក៏និយាយជាមួយទ្រង់រណឫទ្ធ ?

**ញ៉ុនឆាយ:** បាទ ដោយទូរស័ព្ទ ។

**BARBER:** តើទ្រង់សុំឲ្យលោកធ្វើអ្វី ?

**ញ៉ុនឆាយ:** ឱវាទរបស់ទ្រង់គឺទប់កម្លាំងកងទ័ពយើងនិងការពារជីវិត និងទឹកដី។

**BARBER:** តើលោកកំពុងធ្វើការ(ទាក់ទង)ជាមួយនឹងខ្មែរក្រហមនៅអន្លង់វែង?

**ញ៉ុនឆាយ:** ដូចជាខ្ញុំនិយាយប្រាប់ពីមុន គ្មានខ្មែរក្រហមទៀតទេ តាំងពីប៉ុល-ពត ត្រូវគេថ្កោលទោស។ កងកម្លាំងទាំងនេះបានប្តូរ ដូចជានៅសំឡូត, ប៉ៃលិន, ម៉ាឡៃទៅដល់ព្រះវិហារ។ គេមានស្មារតីច្បាស់លាស់ថា អ្នកណាប្រយុទ្ធហើយសម្លាប់ខ្មែរគឺសត្រូវរបស់ប្រជាជន។ ក្រោយពេលដែលលោកហ៊ុន-សែនសម្លាប់ពួកហ្វ៊ុនស៊ិនប៉ិច គេដឹងថាតើលោកហ៊ុន-សែននឹងសម្លាប់គេឬអត់ទៅថ្ងៃក្រោយ

**BARBER:** បើអញ្ចឹងលោកអាចធ្វើការជាមួយពួកគេទៅហើយ ?

**ញ៉ុនឆាយ:** កងកម្លាំងនៅអន្លង់វែង, ម៉ាឡៃ, ប៉ៃលិន និងកងកម្លាំងរបស់យើងមានទិសដៅតែមួយ។ កងកម្លាំងនិមួយៗធ្វើសកម្មភាពដោយខ្លួន ប៉ុន្តែយើងមានទិសដៅតែមួយ គឺប្រយុទ្ធជាមួយទាហានរបស់លោកហ៊ុន-សែន ។

**BARBER:** តើលោក(គិត)ដឹងថាកងកម្លាំងនៅប៉ៃលិននិងម៉ាឡៃមានសេចក្តីយល់ព្រមជាមួយនឹងកងកម្លាំងរបស់ហ្វ៊ុនស៊ិនប៉ិច ?

**ញ៉ុនឆាយ:** បាទ យើងដូចគ្នាទាំងអស់ ។

**BARBER:** តើលោកចាត់ថាទឹកដីដែលត្រួតត្រាដោយកងទ័ពប្រឆាំង(ជាមួយលោកហ៊ុន-សែន) មានខាងជើងនៃប្រទេសខ្មែរចុះទៅម៉ាឡៃនិងប៉ៃលិន ?

**ញ៉ុនឆាយ:** ពីព្រះវិហារទៅសំឡូត ។

**BARBER:** តើនៅពេលណា បើគ្មានដំណោះស្រាយផ្លូវទូតទេ កងទ័ពនៅតំបន់ទាំងនោះនឹងប្រយុទ្ធជាមួយកងទ័ពលោកហ៊ុន-សែន ?

**ញ៉ុនឆាយ:** ពេលឆាប់ៗនេះ។ យើងនឹងប្រយុទ្ធដណ្តើមយកតំបន់ខ្លះៗ ។

**BARBER:** លោកបានធ្វើទាហានច្រើនឆ្នាំមកហើយ ហើយមានការពិសោធន៍ក្នុងឆ្នាំ១៩៨០ប្លាយជាអ្នកតស៊ូ។ តើនេះដូចជាពេលវេលាត្រឡប់ថយក្រោយចំពោះលោក ?

**ញ៉ុនឆាយ:** បាទ ប៉ុន្តែខ្ញុំឥឡូវនេះគ្រាន់បើជាងពីមុន។ ពេលមុនយើងខំរស់រយៈពេល១០ឆ្នាំ។ តែឥឡូវនេះមិនយូរដូចមុនទេ ប្រហែលជាបីឬបួនខែ។ ខ្ញុំជឿជាក់ថាយើងនឹងឈ្នះ។ ទីមួយទឹកដីរបស់យើងធំជាងពីមុននៅពេលដែលយើងចាប់ផ្តើមតស៊ូដំបូង (ឆ្នាំ៨០ប្លាយ)។ ទីពីរយើងមានកងកម្លាំងគ្រប់គ្រាន់។ ទីបីយើងមានការគាំទ្រពីប្រជាជនខាងក្នុងនិងខាងក្រៅប្រទេសខ្មែរ។ ប្រជាជនខ្មែរត្រូវការប្រព័ន្ធប្រជាធិបតេយ្យ មិនមែនកុម្មុយនិស្ត ។

**BARBER:** តើលោកគិតយ៉ាងម៉េចចំពោះការតែងតាំងលោក អ៊ុង-ហួត ជានាយករដ្ឋមន្ត្រីទីមួយ ?

**ញ៉ុនឆាយ:** ទីមួយ វាខុសច្បាប់។ នេះគឺជាល្បិចយ៉ាងតូចមួយរបស់លោកហ៊ុន-សែន ហើយអ៊ុង-ហួត គ្រាន់តែជាតុក្កតាមួយ។ លោកហ៊ុន-សែនគ្រាន់តែចង់លេងល្បែងជាមួយនឹងសហគមន៍អន្តរជាតិ ហើយនិងប្រទេសអាស៊ាន (ASEAN) ។ តាមពត៌មានដែលខ្ញុំបានពីមិត្តភក្តិ អ្នកធំៗខាងហ្វ៊ុនស៊ិនប៉ិចនៅភ្នំពេញដូចជារដ្ឋមន្ត្រីឬកុង្សី លើកលែងតែអ៊ុង-ហួត គេទាំងអស់គ្នាមានអង្គរក្សផ្ទាល់ខ្លួនរបស់គេ។ លើកលែងតែអ៊ុង-ហួត គាត់មានអង្គរក្សរបស់លោកហ៊ុន-សែន។ ចំពោះលោកធំៗរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច គេទាំងអស់នៅក្នុងគ្រោះថ្នាក់។ លោកហ៊ុន-សែននឹងរករបៀបចោទប្រកាន់ថ្កោលទោស ហើយយកគេទាំងអស់ទៅតុលាការម្តងមួយៗ ។

**BARBER:** តើលោកមានការខកចិត្តចំពោះលោកធំៗខ្លះរបស់ហ្វ៊ុនស៊ិនប៉ិចដែលសម្ងំនៅភ្នំពេញ ហើយដូចជាត្រូវជាមួយលោកហ៊ុន-សែន ?

**ញ៉ុនឆាយ:** ខ្ញុំមិនខកចិត្តទេ។ មានជនហ្វ៊ុនស៊ិនប៉ិចមួយចំនួនតូចដែលត្រូវលោកហ៊ុន-សែនទិញបាន។ ប៉ុន្តែអ្នកធំៗរបស់ហ្វ៊ុនស៊ិនប៉ិចជាច្រើននៅភ្នំពេញខំប្រឹងប្រែងធ្វើការជាមួយលោកហ៊ុន-សែន ពីព្រោះត្រូវគេគំរាម។ គេខំរកផ្លូវដើរដើម្បីរស់។ គេគ្មានផ្លូវរត់។ លោកហ៊ុន-សែន បានប្រាប់ទៅអាជ្ញាធរថៃថាកុំសំបុត្រឆ្លងដែន (VISA) ទៅខ្មែរ។ អញ្ចឹងហើយបានជាអ្នកទាំងនេះត្រូវគេបំភ័យ គំរាមកំហែង បន្តិចម្តងៗ ។

**BARBER:** បើសិនជាលោកអាចនិយាយទៅលោកហ៊ុន-សែន បើលោកអាចឃើញគាត់ឥឡូវនេះ តើលោកនិយាយអ្វីទៅគាត់ ?

**ញ៉ុនឆាយ:** ខ្ញុំគ្មានអ្វីនិយាយប្រាប់គាត់ទេ ពីព្រោះគាត់សាហាវព្រៃផ្សៃជាងប៉ុល-ពតទៅទៀត។ ខ្ញុំមិនដែលគិតទេថា លោកហ៊ុន-សែនអាចក្លាយទៅមនុស្សព្រៃផ្សៃដូចអញ្ចឹង ។

*ប្រែសម្រួលពីកាសែត Phnom Penh Post*



សូមខ្មែរគ្រប់រូបកុំភ្លេចខ្លួន!